ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១២

# សេចក្តីប្រកាសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹង ទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងសំណុំរឿង ០០៤

ការិយាល័យសហចៅក្រមស៊ើបអង្កេតបានទទួលនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងការស៊ើបសួរបន្ថែមនៅក្នុងសំណុំរឿង ០០៤។ ទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលស្ថិតនៅក្រោមការស៊ើបសួរនៅក្នុងសុំណុំរឿង ០០៤ មិនទាន់ត្រូវបានផ្សព្វផ្សាយជាសាធារណៈ។ ស្របតាមវិធានផ្ទៃក្នុង ២១(១)(គ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិសូមចេញផ្សាយព័ត៌មានខាងក្រោមនេះអំពីទីតាំងទាំងនោះ៖

## ទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងសំណុំរឿង ០០៤

**ក) ខេត្តបាត់ដំបង**

- ***មន្ទីរសន្តិសុខធិបតី*** និង***ការដ្ឋានទួលម្ទេស*** ស្ថិតនៅឃុំធិបតី ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង
- ***ភ្នំត្រជាក់ចិត្ត*** និង***អន្លង់វិលប្រែង*** ស្ថិតនៅភូមិឫស្សីព្រះ ឃុំឆ្នាល់មាន់ ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង
- ***មន្ទីរសន្តិសុខតំបន់ ១***និង***កន្លែងសម្លាប់ដំណាក់វាំង*** ស្ថិតនៅភូមិបាណន់ ឃុំកន្ទឺ ស្រុកបាណន់ ខេត្តបាត់ដំបង

**ខ) ខេត្តពោធិ៍សាត់**

- ***រណ្តៅទួលសេះញ៉ូវ*** និង***វាលពិឃាតព្រៃក្របៅ*** ស្ថិតនៅឃុំរំលេច និងឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***គុកភូមិវាល*** ស្ថិតនៅឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***គុកស្វាយជ្រុំ ហៅគុកភូមិថ្លោល*** និង***គុកបឹងបាតកណ្តាល ហៅត្រាចក្រោល*** ស្ថិតនៅឃុំបឹងបាតកណ្តាល ស្រុកបាកាន ខេត្តពោធិ៍សាត់(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***ទីតាំងសម្លាប់ វត្តច័ន្ទរង្សី-រណ្តៅសាកសពរួម*** និង***អណ្តូងសាកសពរួមនៅភូមិកូនត្នោត ឬ ភូមិចាម*** ស្ថិតនៅឃុំរំលិច ស្រុកបាកាន ខេត្តពោធិ៍សាត់*(ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)*។
- ***កន្លែងសម្លាប់វាលបាក់ចិញ្ចៀន*** *ស្ថិតនៅឃុំស្រែស្តុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ (ការប្រព្រឹត្តទៅលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា)*។

ផ្លូវជាតិលេខ៤ ស/ក ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ ប្រអប់សំបុត្រ ៧១ ទូរស័ព្ទ (៨៥៥) ០២៣-២១៩-៨១៤ ទូរសារ (៨៥៥) ០២៣-២១៩-៨៤១ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chau, Porsenchey, PO Box 71, Phnom Penh, Cambodia Tel: (855) 023 219 814 Fax: (855) 023 219 841 Web: www.eccc.gov.kh

**គ. ខេត្តតាកែវ**

- ***“កន្លែងសម្លាប់ព្រៃសុខុន”*** និង ***“មន្ទីរឃុំឃាំងវត្តអង្គសិរីមុនី”*** ស្ថិតនៅភូមិស៊ីស្លា ឃុំផ្លាប្រជុំ ស្រុកកោះអណ្តែត ខេត្តតាកែវ(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***ព្រៃភូមិស្តែង វត្តអង្គុញ កន្លែងសម្លាប់ភូមិព្រាល*** និង***ភូមិសោម*** និង***គុកវត្តសុបិន*** ស្ថិតនៅឃុំគោកព្រេច និងឃុំកំពែង ស្រុកគិរីវង្ស ខេត្តតាកែវ(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***មន្ទីរសន្តិសុខវត្តប្រធាតុ*** ស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគិរីវង្ស ខេត្តតាកែវ(ការប្រព្រឹត្តទៅលើខ្មែរក្រោម)
- ***មន្ទីរសន្តិសុខក្រាំងតាចាន់*** ស្ថិតនៅស្រុកត្រាំកក់ ខេត្តតាកែវ(ការប្រព្រឹត្តទៅលើខ្មែរក្រោម និងជនដទៃទៀត)

**ឃ. ខេត្តកំពង់ធំ**

- ***“គុកសម័យអាណានិគមនៅកំពង់ធំ”*** ស្ថិតនៅទីរួមខេត្តកំពង់ធំ ខេត្តកំពង់ធំ (ការបោសសម្អាតភូមិភាគកណ្តាល)

**ង. ខេត្តកំពង់ចាម**

- ***“កន្លែងសម្លាប់ថ្នល់បែក”*** ស្ថិតនៅឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម(ទាក់ទងនឹងមន្ទីរសន្តិសុខវត្តបារាយជាន់ដែក)

* * *

សាក្សី ឬជនរងគ្រោះណា ដែលមានព័ត៌មានទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មខាងលើទាំងនេះ អាចទាក់ទងអង្គភាពគាំពារជនរងគ្រោះនៃអ.វ.ត.ក ដើម្បីទទួលព័ត៌មានបន្ថែមអំពីភ័ស្តុតាង និងលក្ខខណ្ឌដែលអាចដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី។


**អង្គភាពគាំពារជនរងគ្រោះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ផ្លូវជាតិលេខ ៤

សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ភ្នំពេញ

ប្រអប់សំបុត្រលេខ ៧១

ទូរស័ព្ទការិយាល័យ: ០២៣ ៨៦១ ៨៩៣ ឬទូរស័ព្ទសម្រាប់ប្រឹក្សា: ០៩៧ ៧៤២ ៤២១៨

ការិយាល័យបើកធ្វើការពីថ្ងៃ ច័ន្ទ ដល់ថ្ងៃ សុក្រ លើកលែងថ្ងៃបុណ្យនិងថ្ងៃឈប់សម្រាក។